# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៧

**លើឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨ សម្រាប់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកគងពិសី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ស្រុកបាទី ខេត្តតាកែវ ស្រុកកណ្តាលស្ទឹង និងស្រុកអង្គស្នួល ខេត្តកណ្តាល**

**សម្រាប់ការដកតំបន់ចែកចាយ**

# DECISION ON THE SEVENTH REVISION

OF THE LICENSE DOCUMENT No.224 LD DATED AUGUST 20, 2008 OF SOKHA ELECTRICITY CO., LTD FOR PROVIDING ELECTRIC POWER SERVICES AT SOME PART OF KONGPISEY, SAMRONGTONG DISTRICTS, KAMPONG SPEU PROVINCE, BATY DISTRICT, TAKEO PROVINCE, KANDAL STUNG AND ANGSNUOL DISTRICTS, KANDAL PROVINCE

**FOR WITHDRAWING DISTRIBUTION AREA**

ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥

AUGUST 26, 2015

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ ៤២៤ សរ -១៥-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៧ លើឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨ សម្រាប់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី

# DECISION ON THE SEVENTH REVISION OF THE LICENSE DOCUMENT No.224 LD DATED AUGUST 20, 2008 FOR SOKHA ELECTRICITY CO., LTD

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យដោយ ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨

-Refer to the License Document No.224 LD issued by Electricity Authority of Cambodia to Sokha Electricity Co., Ltd on August 20, 2008.

-យោងលិខិតស្នើសុំរបស់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី លេខ ០០៨/១៥.សខអ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥

- Refer to the requested letter of Sokha Electricity Co., Ltd No. 008/15 dated March 10, 2015.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០១៥ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥

- In accordance with the consultation with concerned parties and public, made from July 07, 2015 to August 15, 2015.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ២៨២ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥

- In accordance with the decision of Electricity Authority of Cambodia's Session No. 282, dated August 26, 2015.

# សម្រេច
# DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ ២០០៨ ដែលបានផ្តល់ជូនក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាបណ្ណ**" ) សម្រាប់ធ្វើសេវាកម្មអគ្គិសនីក្នុងតំបន់អនុញ្ញាតដែលកំណត់ក្នុងឧបសម្ព័ន្ធទី២ ដើម្បីផ្តល់សិទ្ធិឲ្យអ្នកកាន់អាជ្ញាបណ្ណដូចខាងក្រោម: | **Article 1**<br>To revise the license document No.224 LD dated August 20, 2008 issued to **Sokha Electricity Co., Ltd** (herein after referred to as "**Licensee**") to supply the electric power service in authorized distribution areas is determined in schedule 2 : |
| -អនុញ្ញាតឲ្យអ្នកកាន់អាជ្ញាបណ្ណ ដកតំបន់ចែកចាយអគ្គិសនីផ្នែកខ្លះនៃស្រុកគងពិសី និងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីតំបន់ចែកចាយរបស់ខ្លួនឲ្យទៅលោក អ៊ុង យុនវឌ្ឍនៈ កាន់អាជ្ញាបណ្ណលេខ ៣៨៦ អ ធ្វើសេវាកម្មអគ្គិសនីជំនួសវិញ មានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ កែសម្រួលថ្មី ។ | - To allow licensee to withdraw some part of Kongpisey and Borseth Districts, Kampong Speu Province from existing distribution area and transfer the management to Mr. Ung Kunvathanak license No. 386 LD as shown in the attached map in new revised schedule 2. |
| -អនុញ្ញាតឲ្យអ្នកកាន់អាជ្ញាបណ្ណ ដកតំបន់ចែកចាយអគ្គិសនីផ្នែកខ្លះនៃឃុំស្វាយចចិប ស្រុកបសេដ្ឋ ឃុំព្រៃក្មេង និងឃុំគិរីវ័ណ្ណ ស្រុកភ្នំស្រួច ឃុំមហាសាំង ឃុំធម្មតាអរ និងឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចេញពីតំបន់ចែកចាយរបស់ខ្លួនឲ្យទៅលោកស្រី ចាន់ គីមអេង កាន់អាជ្ញាបណ្ណលេខ ៣៨៥ អ ធ្វើសេវាកម្មអគ្គិសនីជំនួសវិញ មានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ កែសម្រួលថ្មី ។ | - To allow licensee to withdraw some part of Khum Svay Chocheb, Borseth District, Khum Prey Kmeng and Khum Kirivorn, Phnom Sruoch District and some part of Khum Moha Sang, Khum Thummoda Or and Khum Kraing Ampil, Somrongtong District, Kompong Speu Province from existing distribution area and transfer the management to Mrs. Chan Kim Eng license No. 385 LD as shown in the attached map in new revised schedule 2. |
| -អនុញ្ញាតឲ្យអ្នកកាន់អាជ្ញាបណ្ណ ដកតំបន់ចែកចាយអគ្គិសនីផ្នែកខ្លះនៃឃុំរកាកោះ និងឃុំព្រះនិព្វាន្ត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ចេញពីតំបន់ចែកចាយរបស់ខ្លួនឲ្យទៅលោក អ៊ុង យុនវឌ្ឍនា កាន់អាជ្ញាបណ្ណលេខ ៤១១ អ ធ្វើសេវាកម្មអគ្គិសនីជំនួសវិញ មានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ កែសម្រួលថ្មី ។ | - To allow licensee to withdraw a part of Khum Roka Koh and Khum Preah Nipean, Kongpisey District, Kampong Speu Province from existing distribution area and transfer the management to Mr. Ung Khunvathana license No. 411 LD as shown in the attached map in new revised schedule 2. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី២ចាស់ នៃឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី២ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 2 of the license document No. 224 LD is replaced by the new revised schedule 2 attached herewith. |
| **ប្រការ៣**<br>ខ្លឹមសារ និងលក្ខខណ្ឌដទៃទៀតនៃឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 3**<br>The other contents and conditions of the license document No. 224 LD shall remain unaltered and in force |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ។ | **Article 4**<br>This decision shall be considered as a part of license document No. 224 LD. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>This decision shall come into force from the date of signing. |

| | |
|---|---|
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាបណ្ណ ត្រូវផ្ញើសេចក្ដីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ បានតម្កល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាបណ្ណលេខ ២២៤ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្ដីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 224 LD has been deposited in order that the deposited license document No. 224 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥

Phnom Penh, August 26, 2015

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

**បណ្ឌិត.ទី នរិន្ទ**

# ឧបសម្ព័ន្ធទី២
# តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី ២៨២ នាថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៥

## SCHEDULE 2
## AUTHORIZED DISTRIBUTION AREAS
## AS AMENDED IN SESSION OF EAC No. 282 DATED AUGUST 26, 2015

| | |
|---|---|
| ១- តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី ដែលអ្នកកាន់អាជ្ញាបណ្ណមានសិទ្ធិផ្តល់សេវាចែកចាយ និងផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់គឺនៅផ្នែកខ្លះនៃស្រុកគងពិសី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ស្រុកបាទី ខេត្តតាកែវ ស្រុកកណ្តាលស្ទឹង និងស្រុកអង្គស្នួល ខេត្តកណ្តាល ។ | 1. The authorizes distribution Areas, where the licensee have the right to provide the electricity distribution and supply services are some parts of Kongpisey and Kamrongtong Districts, Kampong Speu Province, Baty District, Takeo Province, Kandal Stung and Angsnuol Districts, Kandal Province. |
| ២- តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី កំណត់ដោយ “ផែនទីកំណត់ព្រំប្រទល់លេខ 224LD-Sokha Electricity-LR7–MR6 -2015” ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution areas is determined by “the boundary map No. 224LD-Sokha Electricity-LR7–MR6-2015 ” attached. |
| ៣- ក្នុងក្របខណ្ឌនៃអាជ្ញាបណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាបណ្ណមានបំណងស្នើសុំពង្រីកឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាបណ្ណត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឲ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី២នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឲ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if the licensee intends to request the extension or the additional distribution areas then licensee shall prepare all necessary documents and submit to EAC in accordance with the EAC’s determination. After EAC authorized to extend or to add distribution area, this schedule 2 shall be revised and attached with that authorization. |

# តំបន់ចែកចាយអគ្គិសនីរបស់ក្រុមហ៊ុន សុខា អេឡិចទ្រីស៊ីធី

224LD-Sokha Electricity-LR7-MR6-2015
Session no.282 on August 26, 2015
PCS: Indian 1960 UTM Zone 48N

## ផ្នែកខ្លះនៃស្រុកគងពិសី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ស្រុកបាទី ខេត្តតាកែវ ស្រុកកណ្ដាលស្ទឹង និងស្រុកអង្គស្នួល ខេត្តកណ្ដាល



អអក

EAC

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្ដីសម្រេចកែសម្រួលលើកទី៦
## លើឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨ សម្រាប់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកគងពិសី ស្រុកសំរោងទង ស្រុកបសេដ្ឋ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ស្រុកបាទី ខេត្តតាកែវ ស្រុកកណ្ដាលស្ទឹង និងស្រុកអង្គស្នួល ខេត្តកណ្ដាល
## សម្រាប់ការដកតំបន់ចែកចាយ

## DECISION ON THE SIXTH REVISION

OF THE LICENSE DOCUMENT No.224 LD DATED AUGUST 20, 2008 OF SOKHA ELECTRICITY Co., Ltd FOR PROVIDING ELECTRIC POWER SERVICES AT SOME PARTS OF KONGPISEY, SAMRONGTONG, BORSETH, PHNOM SRUOCH DISTRICTS, KAMPONG SPEU PROVINCE, BATY DISTRICT, TAKEO PROVINCE, KANDAL STEUNG AND ANGSNUOL DISTRICTS, KANDAL PROVINCE

## FOR WITHDRAWING DISTRIBUTION AREA

ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

JUNE 13, 2014

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ ២១៧ សរ - ១៤-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៦ លើឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨ សម្រាប់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី

# DECISION ON THE SIXTH REVISION OF THE LICENSE DOCUMENT No.224 LD DATED AUGUST 20, 2008 FOR SOKHA ELECTRICITY Co., Ltd

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨

-Refer to the License Document No.224 LD issued by Electricity Authority of Cambodia to Sokha Electricity Co., Ltd on August 20, 2008.

-យោងលិខិតស្នើសុំកាត់តំបន់របស់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី លេខ. ០១/១៣លស.សខអ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣

-Refer to the requested withdrawing area letter of Sokha Electricity Co., Ltd No. 01/13 dated February 05, 2013.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៣

- In accordance with the consultation with concerned parties and public, made from November 13, 2013 to December 15, 2013.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី២៦២ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៤

- In accordance with the decision of **Electricity Authority of Cambodia's** Session No. 262, dated June 13, 2014.

# សម្រេច
# DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ ២០០៨ ដែលបានផ្តល់ជូន**ក្រុមហ៊ុន សុខា អេឡិចទ្រីស៊ីធី** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**" ) សម្រាប់ធ្វើសេវាកម្មអគ្គិសនីក្នុងតំបន់អនុញ្ញាត ដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ ដើម្បីផ្តល់សិទ្ធិឲ្យអ្នកកាន់អាជ្ញាប័ណ្ណដកតំបន់ចែកចាយអគ្គិសនីមួយផ្នែកនៃស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ឲ្យទៅ**លោក អ៊ុង យុនវឌ្ឍនៈ** និង ដកតំបន់ចែកចាយអគ្គិសនីមួយផ្នែកនៃស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ឲ្យទៅ**លោកស្រី ចាន់ គីមអេង** ធ្វើសេវាកម្មអគ្គិសនីជំនួសវិញ ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ។ | **Article 1**<br>To revise the license document No. 224 LD dated August 20, 2008 issued to Sokha Electricity Co., Ltd (herein after referred to as "Licensee") to supply the electric power service in authorized distribution area is determined in schedule 1, by withdrawing some part of Borseth District, Kampong Speu Province to Mr. Ung Khunvathanak and some part of Phom Sruoch District, Kampong Speu Province to Mrs. Chan Kim Eng from existing distribution areas as shown in the attached map in new revised schedule 1. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី១ចាស់ នៃឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 1 of the license document No. 224 LD is replaced by the new revised schedule 1 attached herewith. |
| **ប្រការ៣**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article3**<br>The other contents and conditions of the license document No. 224 LD shall remain unaltered and in force. |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ។ | **Article 4**<br>This decision shall be considered as a part of license document No. 224 LD. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ បានតម្កល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 224 LD has been deposited in order that the deposited license document No. 224 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

Phnom Penh, June 13, 2014

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

**បណ្ឌិត.ទី នរិន្ទ**

# ឧបសម្ព័ន្ធទី១
# តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី២៦២ នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៤

## SCHEDULE 1
## AUTHORIZED DISTRIBUTION AREAS
## AS AMMENDED IN SESSION OF EAC No.262 DATED JUNE 13, 2014

| | |
|---|---|
| ១- តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី ដែលអ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្តល់សេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់គឺនៅផ្នែកខ្លះនៃស្រុកគងពិសី ស្រុកសំរោងទង ស្រុកបសេដ្ឋ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ស្រុកបាទី ខេត្តតាកែវ ស្រុកកណ្តាលស្ទឹង និងស្រុកអង្គស្នួល ខេត្តកណ្តាល ។ | 1. The authorizes distribution Areas, where the licensee have the right to provide the electricity distribution and supply service are some part of Kongpisey, Samrongtong, Borseth Phnom Sruoch Districts, Kampong Speu Province, Baty District, Takeo Province, Kandal Steung and Angsnuol Districts, Kandal Province. |
| ២- តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី កំណត់ដោយ "ផែនទីកំណត់ព្រំប្រទល់លេខ 224 LD- Sokha Electricity Co., Ltd-LR6-MR5-2014" ដែលភ្ជាប់មកជាមួយ។ | 2. The authorized distribution areas are determined by "the boundary map No. 224LD- Sokha Electricity Co., Ltd-LR6-MR5-2014" attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីកឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឲ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឲ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if the licensee intends to request the extension or the additional distribution areas then licensee shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |

# តំបន់ចែកចាយអគ្គិសនីរបស់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី

224LD-Sokha Electricity-LR6-MR5-2014
Session no.262 on June 13, 2014
PCS: Indian 1960 UTM Zone 48N

## ផ្នែកខ្លះនៃស្រុកកងពិសី ស្រុកសំរោងទង ស្រុកបសេដ្ឋ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ស្រុកបាទី ខេត្តតាកែវ ស្រុកកណ្តាលស្ទឹង និងស្រុកអង្គស្នួល ខេត្តកណ្តាល



## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
## ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# អាជ្ញាប័ណ្ណចែកចាយសម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនី នៅតំបន់ស្រុកសំរោងទង និងតំបន់ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

# DISTRIBUTION LICENSE FOR PROVIDING ELECTRIC POWER DISTRIBUTION SERVICE AT SAMRAONG TONG AND KORNG PISEY DISTRICT, KAMPONG SPEU PROVINCE

## ក្រុមហ៊ុន សុខា អេឡិកត្រិស៊ីធី
## SOKHA ELECTRICITY CO., LTD

ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨

AUGUST 20, 2008

# ផ្នែកទី១

# សេចក្តីសម្រេចផ្តល់សិទ្ធិឱ្យធ្វើសេវាកម្ម

# PART I

# DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE

**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**NATION RELIGION KING**

**អាជ្ញាធរអគ្គិសនីកម្ពុជា**
ELECTRICITY AUTHORITY OF CAMBODIA
លេខ : ០៨-អអក

# ឯកសារអាជ្ញាប័ណ្ណលេខ ២២៤ ឯអ
# LICENSE DOCUMENT NO. 224LD

# អាជ្ញាប័ណ្ណចែកចាយសម្រាប់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី
# DISTRIBUTION LICENSE FOR SOKHA ELECTRICITY CO., LTD

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧, ២៩ និង ៣៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ២០០១
- In exercise of the powers conferred by Article 7, 29 and 34 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated February 02, 2001.
- យោងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ១២៨ ឧរថ អថ.ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨
- In accordance with PRAKAS of Ministry of Industry, Mines and Energy Nº 128 dated February 05, 2008.
- យោងតាមកិច្ចព្រមព្រៀងលក់-ទិញអគ្គិសនី ដែលចុះហត្ថលេខារវាងក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨
- In accordance with Power Purchase Agreement signed between Electricité du Cambodge and Sokha Electricity Co., Ltd, dated March 21, 2008.
- យោងតាមពាក្យស្នើសុំអាជ្ញាប័ណ្ណចែកចាយរបស់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី លេខ ០០២/០៨ សអ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៨
- In accordance with the application for distribution license of Sokha Electricity Co., Ltd, No.002/08 dated February 08, 2008.
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកស្នើសុំអាជ្ញាប័ណ្ណ ស្ថាប័នពាក់ព័ន្ធ និងសាធារណជន ចាប់ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨
- In accordance with the consultations with the applicant, concerned parties and public, made from May 20, 2008 to June 20, 2008.
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ១៣៦ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨
- In accordance with the decision of Electricity Authority of Cambodia's Session No. 136 dated August 20, 2008.

# សម្រេច

# DECIDES

| | |
|---|---|
| **ប្រការ១** | **Article 1** |
| ផ្តល់អាជ្ញាប័ណ្ណចែកចាយជូន **ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី** (បន្ទាប់ពីនេះហៅថា“**អ្នកកាន់អាជ្ញាប័ណ្ណ**”) មានទីស្នាក់ការផ្ទះលេខ ៤ $AE_0$ ផ្លូវលេខ ១៤១ សង្កាត់បឹងព្រលឹត ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ ដែលបានចុះបញ្ជីពាណិជ្ជកម្ម លេខ Co.១១៣២០/០៨P ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ នៅក្រោមបទប្បញ្ញត្តិនៃក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយអគ្គិសនីនៅតំបន់ស្រុកសំរោងទង និងតំបន់ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយទិញអគ្គិសនីពីក្រុមហ៊ុន អគ្គិសនីកម្ពុជា ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងលក់–ទិញអគ្គិសនីរវាងក្រុមហ៊ុន អគ្គិសនីកម្ពុជា និងក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី ដែលបានចុះហត្ថលេខានៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ ។ | There is hereby granted the Distribution License to **Sokha Electricity Co., Ltd** (herein after referred to as "Licensee") located at #4AE0, St. 141, Sangkat Beung Bralit, Khan Brampi Makara, Phnom Penh, registered in the Kingdom of Cambodia under No. Co.11320/08P dated January 14, 2008 pursuant to the Commercial and Civil Law for grant of the right to licensee to distribute electricity at Samraong Tong and Korng Pisey District, Kampong Speu Province by purchasing electricity from Electricite du Camboge under the purchase agreement (PPA) between **Electricite du Cambodge** and **Sokha Electricity Co., Ltd**, which was signed on March 21, 2008. |
| សិទ្ធិខាងលើ ត្រូវអនុលោមទៅតាមល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណដែលមានចែងក្នុងផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។ | The above right shall be in accordance with conditions of license specified in part 2 of this license. |
| **ប្រការ២** | **Article 2** |
| ល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណនេះអាចកែសម្រួល ឬ ធ្វើវិសោធនកម្មបានអនុលោមតាមបញ្ញត្តិរបស់អាជ្ញាប័ណ្ណនេះ ឬតាមមាត្រា ៧ និង ៤៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណដែលផ្តល់ឱ្យនេះអាចដកហូតបាន ស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃផ្នែកទី២ របស់អាជ្ញាប័ណ្ណ ។ | The License Conditions referred to above are subject to modification or amendment in accordance with their terms or with Article 7 and 44 of the Electricity Law of Cambodia. This license hereby granted is further subject to the terms of revocation specified in Schedule 2 of Part II of this License. |
| **ប្រការ៣** | **Article 3** |
| អាជ្ញាប័ណ្ណនេះត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងមានអាណត្តិចំនួន ១៥ (ដប់ប្រាំ) ឆ្នាំ និងអាចស្នើសុំបន្តទៀតឬស្នើសុំកែសម្រួលបានលើកលែងតែត្រូវបានដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។ | This license shall come into force on the date it is signed and, unless revoked earlier, the term of the license shall be 15 (fifteen) years and on the application of the license may be renewed for further period and with such modification as required. |

ភ្នំពេញ, ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨

Phnom Penh, August 20, 2008

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ផ្នែកទី២

# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ

# PART II

# CONDITIONS OF LICENSE

# តារាងមាតិកា

## TABLE OF CONTENTS


| | |
|---|---|
| **១-និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ** | **1-Definitions of terms used in the license** |
| **២-ភារកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **2-General Obligation of licensee** |
| **ល័ក្ខខ័ណ្ឌទី១ :** កាតព្វកិច្ចគោរពច្បាប់ និងអនុក្រឹត្យ | **Condition 1:** Obligation on compliance with the Law and Sub-decree |
| **ល័ក្ខខ័ណ្ឌទី២ :** កាតព្វកិច្ចគោរពតាមស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន | **Condition 2:** Obligation on compliance with technical standard, safety and environment |
| **ល័ក្ខខ័ណ្ឌទី៣ :** កាតព្វកិច្ចគោរពតាមបទបញ្ជា ឬ សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការដាក់វិធាន និងនីតិវិធីនានាសម្រាប់ការធ្វើសេវាកម្មចែកចាយ | **Condition 3:** Obligation on compliance with order or decision of EAC in issuing rules and regulations for distribution service a |
| **ល័ក្ខខ័ណ្ឌទី៤ :** កាតព្វកិច្ចគោរពតាមល័ក្ខខ័ណ្ឌសេវាកម្មដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន | **Condition4:** Obligation on compliance with conditions of electric power service specified in its license |
| **ល័ក្ខខ័ណ្ឌទី៥ :** កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួនតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា | **Condition5:** Obligation on Financial statement and its electric power service report in accordance with EAC's adoption |
| **ល័ក្ខខ័ណ្ឌទី៦ :** កាតព្វកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ | **Condition6:** Obligation on payment of license fee |
| **៣-ល័ក្ខខ័ណ្ឌសេវាកម្ម** | **3-SERVICE CONDITIONS** |
| **ល័ក្ខខ័ណ្ឌទី៧ :** ល័ក្ខខ័ណ្ឌចំពោះតំបន់ធ្វើសេវាកម្ម | **Condition 7:** Condition on electric power service area |
| **ល័ក្ខខ័ណ្ឌទី៨ :** ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម | **Condition 8:** Condition on electric power service utilities |
| **ល័ក្ខខ័ណ្ឌទី៩ :** ល័ក្ខខ័ណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ | **Condition 9:** Condition on distribution system operation |
| **ល័ក្ខខ័ណ្ឌទី១០ :** ល័ក្ខខ័ណ្ឌចំពោះការធ្វើអាជីវកម្មអគ្គិសនី | **Condition 10:** Condition on electric power business |
| **ល័ក្ខខ័ណ្ឌទី១១ :** ល័ក្ខខ័ណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន | **Condition 11:** Condition on electric power supply to customers |
| **ល័ក្ខខ័ណ្ឌទី១២ :** ល័ក្ខខ័ណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ | **Condition 12:** Condition on public interest |
| **ល័ក្ខខ័ណ្ឌទី១៣ :** ការទំនាក់ទំនង | **Condition 13**: Communication |
| **ល័ក្ខខ័ណ្ឌទី១៤ :** ល័ក្ខខ័ណ្ឌលក់មធ្យោបាយចែកចាយ ក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា | **Condition 14**: Sale Condition of distribution facility in the case it is required from EAC |
| **ឧបសម្ព័ន្ធទី១ :** តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី | **Schedule 1:** Authorized distributing area |
| **ឧបសម្ព័ន្ធទី២ :** ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ | **Schedule 2:** Term of revocation |
| **ឧបសម្ព័ន្ធទី៣:** ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ | **Schedule 3:** Ownership of Licensee |

# ល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ

# CONDITIONS OF LICENSE

## ១_និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ

ពាក្យពេចន៍ទាំងឡាយណាដែលបានប្រើប្រាស់ក្នុងឯកសារអាជ្ញាប័ណ្ណនេះ ឬផ្នែកណាមួយរបស់ឯកសារនេះ និងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ត្រូវមានន័យដូចខាងក្រោម :

| | |
|---|---|
| "សវនកម្ម" | មានន័យថា ការជំរះបញ្ជីលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណដោយសវនករមួយ ក្នុងពេលធ្វើអាជីវកម្ម ។ |
| "ល័ក្ខខ័ណ្ឌ" | មានន័យថាល័ក្ខខ័ណ្ឌចែងក្នុងអាជ្ញាប័ណ្ណនេះ ។ |
| "ថ្លៃភ្ជាប់ប្រព័ន្ធ" | មានន័យថា បន្ទុកត្រូវបង់ថ្លៃចំណាយសម្រាប់ការអនុវត្តន៍ការងារ ការផ្តល់សំភារៈ និងការតម្លើងនៃបរិក្ខារអគ្គិសនី ខ្សែបណ្តាញអគ្គិសនី និងនាឡិកាស្ទង់ផ្ទៃក្នុង ក្នុងការសាងសង់ឬការកែសម្រួលចំណុចដែលត្រូវភ្ជាប់ចូល និងភ្ជាប់ចេញនៃប្រព័ន្ធចែកចាយអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។ |
| "អ្នកប្រើប្រាស់" | មានន័យថា បុគ្គលណាមួយ ឬអ្នកទទួលសិទ្ធិបន្តដែលទិញឬទទួលអគ្គិសនីដើម្បីប្រើប្រាស់ និងមិនមែនដើម្បីផ្តល់ ឬលក់បន្តឱ្យអ្នកដទៃទៀតឡើយ ។ |
| "អ្នកប្រើប្រាស់ធុនតូច" | គឺអ្នកប្រើប្រាស ់ដែលទទួលការផ្គត់ផ្គង់ពីខ្សែបណ្តាញសាធារណៈតង់ស្យុងទាប ២៣០វ៉ុល ១ហ្វា និងត្រូវ ការកម្លាំងរហូតដល់ ៦០អំពែរ ឬ៤០០វ៉ុល ៣ហ្វា និងត្រូវការកម្លាំងរហូតដល់ ៩០អំពែរ ។ |
| "អ្នកប្រើប្រាស់ធុនមធ្យម" | គឺអ្នកប្រើប្រាស់ ដែលទទួលការផ្គត់ផ្គង់ពីបន្ទប់ភ្លើង MV/LV តាមទ្វារចរន្តតង់ស្យុងទាបដាច់ដោយឡែក ៤០០វ៉ុល ៣ហ្វា និងមានកម្លាំងលើសពី ៩០អំពែរ រហូតដល់តិចជាង ១៥០អំពែរ។ នាឡិកាស្ទង់ត្រូវតម្លើងនៅលើទ្វារចរន្តនៅក្នុងបន្ទប់ភ្លើងនោះ ។ |
| "អ្នកប្រើប្រាស់ធុនធំ" | គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ជាទូទៅពីបន្ទប់ភ្លើង MV/LV ដាច់ដោយឡែកនៅក្នុងទីតាំងរបស់អ្នកប្រើប្រាស់តាមតង់ស្យុងមធ្យម ៤០០វ៉ុល ៣ហ្វារ និងត្រូវការកម្លាំងលើសពី ១៥០អំពែរ រហូតដល់ |

## 1-DEFINITIONS OF TERMS USED IN THE LICENSE

In this or any of the following Parts of this document and in the Schedules below, unless otherwise specified or the context otherwise requires:

| | |
|---|---|
| "Audit" | means audit on the licensee's financial statement of financial year by an auditor. |
| "Condition" | means a Condition set out in this License. |
| "Connection charges" | means charges made for carrying out works and provision and installation of electrical plant, electric lines and meters in constructing or modifying entry and exit points on the Licensee's Distribution System to give supply to a consumer. |
| " Consumer" | means a person or his authorized representative that purchases or receives electricity for consumption and not for delivery or resale to others. |
| "Small Consumers" | mean a consumer requiring power up to 60 amperes at single phase 230 volts or up to 90 amperes at three phase 400 volts is categorized as Small Consumer. Small Consumers will be supplied power from the public LV network. |
| "Medium Consumers" | mean a consumer requiring power more than 90 amperes and less than 150 amperes at three phase 400 volts is categorized as Medium Consumer. Medium Consumers will be supplied power through a separate LV feeder from the MV/LV substation. The meter will be installed at the substation on this feeder. |
| "Big Consumers" | mean a consumer requiring power more than 150 amperes and less than 400 amperes at three phase 400 volts is categorized as Big Consumer. Big Consumers will be |

| | | | |
|---|---|---|---|
| | តិចជាង ៤០០អំពែរ ។ ក្នុងករណីខ្លះ បើអ្នកផ្គត់ផ្គង់ ពិនិត្យឃើញថាអាចអនុវត្តបានសម្រាប់អ្នកប្រើប្រាស់ ដែលប្រើប្រាស់អនុភាពមួយផ្នែកនៃបន្ទប់ភ្លើង ការផ្គត់ផ្គង់អាចបន្តចេញតាមខ្សែតង់ស្យុងទាបដាច់ដោយឡែកពីបន្ទប់ភ្លើងសាធារណៈ ។ នាឡិកាស្ទង់ត្រូវតម្លើងនៅលើទ្វារចរន្តនៅបន្ទប់ភ្លើងនោះ ។ | | supplied power generally from a separate MV/LV substation on their premises. The meter will be installed indoors or close to the substation. In some cases, if found feasible by the licensee, the supply to Big Consumers can be given by partly utilizing the capacity of a public MV/LV substation through a separate LV feeder. The meter will be installed at the substation on this feeder. |
| "អ្នកប្រើប្រាស់តង់ស្យុងមធ្យម" | គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យមពីបណ្តាញតង់ស្យុងមធ្យម និងមានតម្រូវការអនុភាពមិនតិចជាង 275kVA ។ នាឡិកាស្ទង់ តង់ស្យុងមធ្យមត្រូវតម្លើងនៅលើបណ្តាញតង់ស្យុងមធ្យមផ្ទាល់ ។ | "MV Consumers" | mean a consumer requiring power more than 275kVA will be supplied power at MV by a direct connection from the MV network. MV metering will be provide on the MV connection. |
| "អ្នកប្រើប្រាស់ធំ" | គឺអ្នកប្រើប្រាស់ទាំងឡាយណា ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងខ្ពស់ (លើសពី ៣៥,០០០ វ៉ុល) ។ | "Bulk Consumers" | mean a consumer supplied power at high voltage (above 35.000 Volts). |
| "អតិថិជន" | មានន័យថា បុគ្គលណាមួយដែលបានទទួលការផ្គត់ផ្គង់ ឬទាមទារឱ្យមានការផ្គត់ផ្គង់អគ្គិសនីឱ្យទីតាំងខ្លួនក្នុងតំបន់អនុញ្ញាត ។ | "Customer" | means any person supplied or requiring to be supplied with electricity either for own consumption or for delivery or sales to others. |
| "អាជីវកម្មចែកចាយ" | មានន័យថាការធ្វើអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយមានលក្ខណៈជា :<br>(ក)–ការចែកចាយអគ្គិសនី តាមរយៈប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណគិតរួមទាំងអាជីវកម្ម ក្នុងការផ្គត់ផ្គង់ការតភ្ជាប់ប្រព័ន្ធជាមួយប្រព័ន្ធនេះ<br>(ខ)–ការផ្តល់សេវាសម្រាប់នាឡិកាស្ទង់ និង<br>(គ)–ការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។ | "Distribution Business" | means the business of the Distribution Licensee including a business ancillary to:<br>(a) the distribution of electricity through the Licensee's Distribution System, including any business in providing connections to such system;<br>(b) the provision of Metering Services; and<br>(c) the supply of electricity to consumers. |
| "កូដប្រព័ន្ធចែកចាយ" | ជាក្បួនច្បាប់ដែលគ្របដណ្តប់លើទិដ្ឋភាពបច្ចេកទេសធំៗទាំងអស់ដែលពាក់ព័ន្ធជាមួយការតភ្ជាប់ ការដំណើរការ និងការប្រើប្រាស់ប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ឬការដំណើរការខ្សែបណ្តាញ និងបរិក្ខាអគ្គិសនី ដែលបានតភ្ជាប់ជាមួយប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ឬរបស់បុគ្គលណាមួយផ្សេងទៀត ដែលបានទទួលការអនុញ្ញាតឱ្យតភ្ជាប់ជាមួយប្រព័ន្ធរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។ | "Distribution Code" | means the Distribution Code covering all material technical aspects relating to connections to and the operation and use of the Licensee's Distribution System and the operation of electric lines and electrical plant connected to the Distribution System of the Licensee or distribution system of any other person authorized to connect with Licensee's system. |

| | |
|---|---|
| “អាជ្ញាប័ណ្ណចែកចាយ” មានន័យថា អាជ្ញាប័ណ្ណចែកចាយដែលបានផ្តល់ក្នុងប្រការ១ នៃផ្នែកទី ១ ។ | “Distribution License” means the Distribution License granted in Article 1 of Part I. |
| “ប្រព័ន្ធចែកចាយ” មានន័យថា ខ្សែបណ្តាញអគ្គិសនីទាំងអស់របស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងតំបន់ចែកចាយដែលបានអនុញ្ញាត និងខ្សែបណ្តាញអគ្គិសនីណាមួយផ្សេងទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថា ជាផ្នែកនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ព្រមទាំងនាឡិកាស្ទង់ និងបរិក្ខាអគ្គិសនីណាមួយរបស់អ្នកកាន់អាជ្ញាប័ណ្ណដែលបានប្រើប្រាស់សម្រាប់ចែកចាយអគ្គិសនី ដោយអ្នកកាន់អាជ្ញាប័ណ្ណ ដោយឡែកចំពោះអ្នកចែកចាយដទៃណាមួយផ្សេងទៀត វាមានអត្ថន័យដូចគ្នា ដូចមានចែងក្នុងអាជ្ញាប័ណ្ណដែលបានកាន់ដោយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនោះ ។ | “Distribution System” Means all electric lines of the Licensee within the Licensee’s authorized distribution area and any other electric lines which EAC may specify as forming part of the Licensee’s Distribution System, and includes any electrical plant and meters of the Licensee which are used in connection with the distribution of electricity by the Licensee; and, in relation to any other distributor, it shall have the same meaning as it has in the license held by such distributor. |
| “អ្នកចែកចាយ” មានន័យថាបុគ្គលណាមួយដែលបានកាន់អាជ្ញាប័ណ្ណចែកចាយ ។ | “Distributor” means any person who holds a Distribution License. |
| “អាជ្ញាធរអគ្គិសនីកម្ពុជា” មានន័យថា អាជ្ញាធរដែលបានបង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២០១/០៣ ។ | “EAC” means the Electricity Authority of Cambodia established by the Electricity Law promulgated by Royal Decree No. NS/RKM/0201/03. |
| “ឯកសារអាជ្ញាប័ណ្ណ” មានន័ថា គឺជាឯកសារនេះដែលមានពីផ្នែកទី១ ដល់ផ្នែកទី២ និងឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ ។ | “License Document” means this document comprising Parts I, Part II and Schedules 1 to 3. |
| “អ្នកកាន់អាជ្ញាប័ណ្ណ” មានន័យថា **ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី** | “Licensee” means **Sokha Electricity Co., Ltd.** |
| “បរិក្ខានាឡិកាស្ទង់” រួមមាននាឡិកាស្ទង់ និងបរិក្ខាពាក់ព័ន្ធដទៃទៀតដែលមានឥទ្ធិពលផ្ទាល់លើការដំណើរការនាឡិកាស្ទង់នោះ ។ | “Metering equipment” includes any meter and associated equipment, which materially affects the operation of that meter. |
| “ការជូនដំណឹង” មានន័យថា (ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀត) ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬដោយមធ្យោបាយសមស្របណាមួយផ្សេងទៀត ។ | “Notice” means (unless otherwise specified) notice given in writing or by any other reasonable means. |
| “ការបញ្ជាក់” រួមមានការបដិសេធ ឬការសំណូមពរណាមួយដែលបានធ្វើជាលាយលក្ខណ៍អក្សរ ។ | “Representation” includes any objection or any other proposal made in writing. |

## ២ ភារកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ

## 2-GENERAL OBLIGATION OF LICENSEE

### លក្ខខណ្ឌទី១: ភារកិច្ចគោរពច្បាប់ និង អនុក្រឹត្យ

### Condition 1: Obligation on compliance with the Laws and Sub-Decrees

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

1. The Licensee shall comply with the Electricity Law, other Laws and Sub Decrees relating to the Laws.

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមកាតព្វកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងអនុក្រឹត្យនានាពាក់ព័ន្ធនឹងការការពារបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។

2. The Licensee is subjected to the environmental obligations as specified in the Law on Environmental Protection promulgated by the Royal Decree NS/RKM/1296/36, dated 24/12/1996 and Other Sub-Decrees on Environmental Protection of the Kingdom of Cambodia

**លក្ខខណ្ឌទី២: ភាតព្វកិច្ចគោរពតាមស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន**

**Condition 2: Obligation on compliance with technical standard, Safety and Environment**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមស្តង់ដា ទាក់ទងទៅនឹងកិច្ចប្រតិបត្តិការ បច្ចេកទេស សុវត្ថិភាព និងបរិស្ថានដែលបង្កើតឡើង និងផ្សព្វផ្សាយដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

1. The Licensee shall comply with the standards on technical operation, safety and environment, issued and published by Ministry of Industry, Mines and Energy.

**លក្ខខណ្ឌទី៣: ភាតព្វកិច្ចគោរពបទបញ្ជា ឬសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការដាក់វិធាន និងបទប្បញ្ញត្តិនានាសម្រាប់ការធ្វើសេវាកម្មចែកចាយ**

**Condition 3: Obligation on compliance with EAC's order in issuing rules and regulations for distribution service**

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងនីតិវិធីនានា ដែលអាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចដាក់ឱ្យអនុវត្ត សម្រាប់ការធ្វើសេវាកម្មចែកចាយ ។

1. The Licensee shall comply with the provisions of the Rules, Regulations and Procedures on the electric distribution service issued by EAC.

២- ក្នុងករណី និងក្នុងតំបន់ជាក់លាក់ណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ) អាចចេញលិខិតណែនាំ បន្ធូរបន្ថយកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ តាមវាក្យខ័ណ្ឌទី១ ចំពោះផ្នែកណាមួយនៃវិធាន, បទប្បញ្ញត្តិ ឬនីតិវិធី និងតាមទំហំណាមួយ ដែលកំណត់ក្នុងលិខិតណែនាំ ។

2. In specific case and area, EAC may (following consultation with the Licensee) issue directions relieving the Licensee of its obligations under paragraph 1 in respect of such parts of the Rules, Regulations or Procedures and for such areas and for such period as specified in those directions.

**លក្ខខណ្ឌទី៤ : ភាតព្វកិច្ចគោរពលក្ខខណ្ឌសេវាកម្ម ដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន**

**Condition4: Obligation on compliance with service conditions of license**

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមល័ក្ខខ័ណ្ឌសេវាកម្មដែលកំណត់ក្នុងអាជ្ញាប័ណ្ណ ។

1. The Licensee shall comply with the provisions of service Condition stated in this license.

**លក្ខខណ្ឌទី៥ : ភាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួន តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា**

**Condition5: Obligation on Financial statement and reports on electric power service required by EAC**

១- ឆ្នាំការិយបរិច្ឆេទនៃអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវចាប់គិតពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។

1. The financial year of the Licensee shall be reckoned every year from 1st January to the following 31st December.

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវច្បាប់ចំលងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច មិនលើសពី៣ខែ ក្រោយពីបញ្ចប់ឆ្នាំការិយបរិច្ឆេទដែលរបាយការណ៍នោះពាក់ព័ន្ធ ។ ការធ្វើសវនកម្មអាចជំនួសដោយការត្រួតពិនិត្យរបស់អាជ្ញាធរ ក្នុងករណីដែលសភាពការណ៍ជាក់ស្តែងតម្រូវ ។

2. The Licensee shall submit to EAC the copy of its audited financial statement not later than 3 months after the end of financial year to which they relate. The audit can be replaced by the control of EAC in the case that actual situation requires.

៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវបណ្តាពត៌មាន

3. The Licensee shall provide, in the manner and form and at time

ទាំងឡាយ ដែលអាជ្ញាធរទាមទារជាបន្តបន្ទាប់ តាមបែបបទ និងទំរង់កំណត់ដោយអាជ្ញាធរ ដើម្បីអាចឱ្យអាជ្ញាធរផ្ទៀងផ្ទាត់មើលការអនុវត្តន៍របស់អ្នកកាន់អាជ្ញាប័ណ្ណ តាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ និងតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិផ្សេងៗទៀត ។

៤- ដោយមិនគិតពីភាពទូទៅនៃវាក្យខ័ណ្ឌទី៣ អាជ្ញាធរអគ្គិសនីកម្ពុជា អាចទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់នូវព័ត៌មានណាមួយ ឱ្យមានលក្ខណៈលំអិតខ្លាំងជាង ឬខុសពីការផ្តល់ព័ត៌មានធម្មតាដល់អាជ្ញាធរអគ្គិសនីកម្ពុជា ។

**ល័ក្ខខ័ណ្ឌទី៦ : ភាតព្វកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ**

១- ចាប់ពីថ្ងៃចូលជាធរមានរហូតដល់ថ្ងៃបញ្ចប់អាណត្តិនៃអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ **កម្រៃអាជ្ញាប័ណ្ណប្រចាំខែ** តាមអត្រាកម្រៃអាជ្ញាប័ណ្ណ និងរូបមន្តគណនាកម្រៃអាជ្ញាប័ណ្ណ ដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដោយអនុលោមតាមមាត្រា២៧ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣នៃអនុក្រឹត្យស្តីពីការកំណត់កំរិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណ សម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- វិក្កយបត្រនៃកម្រៃអាជ្ញាប័ណ្ណប្រចាំខែ ត្រូវចាត់ទុកថាជំពាក់ និងត្រូវបង់ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអ្នកកាន់អាជ្ញាប័ណ្ណបានទទួលវិក័យប័ត្រ ។

## ៣-ល័ក្ខខ័ណ្ឌសេវាកម្ម

**ល័ក្ខខ័ណ្ឌទី៧: ល័ក្ខខ័ណ្ឌចំពោះតំបន់ធ្វើសេវាកម្ម**

១- អាជ្ញាប័ណ្ណនេះផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណ មានសិទ្ធិធ្វើសេវាកម្មចែកចាយអគ្គិសនី គឺតំបន់ស្រុកសំរោងទង និងតំបន់ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ តំបន់អនុញ្ញាតឱ្យចែកចាយមានកំណត់ទីតាំងច្បាស់លាស់ក្នុងឧបសម្ព័ន្ធទី១ នៃអាជ្ញាប័ណ្ណនេះ (ដូចមានបង្ហាញក្នុងផែនទីដូនភ្ជាប់) ។

២- អ្នកប្រើប្រាស់ធុនធំ និងអ្នកប្រើប្រាស់ដុំក្នុងតំបន់ចែកចាយខាងលើ អាចមានសិទ្ធិជ្រើសរើសប្រភពផ្គត់ផ្គង់ពីប្រព័ន្ធបញ្ជូនឬពីប្រព័ន្ធចែកចាយមេផ្សេងទៀតបាន បើសិនជាមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

**ល័ក្ខខ័ណ្ឌទី៨: ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម**

១- អ្នកកាន់អាជ្ញាប័ណ្ណ មានកាតព្វកិច្ចអភិវឌ្ឍន៍មធ្យោបាយធ្វើសេវាកម្មរបស់ខ្លួន ដើម្បីអាចផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់របស់ខ្លួនបាន និងប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើផែនការនិងអភិវឌ្ឍន៍ប្រព័ន្ធចែកចាយរបស់ខ្លួន ទៅតាមល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដា

determined by EAC, such information as EAC may require from time to time for monitoring the Licensee's compliance with the conditions of this license, provisions of the electricity law and any other legislative or regulatory requirements.

4. Without prejudice to the generality of paragraph 3, EAC may require the Licensee to supply information which is more extensive than or differs from that required to be prepared and supplied to EAC.

**Condition6: Obligation on payment of license fee**

1. From the effective date to end of the term of license, the Licensee shall pay to EAC **"the monthly license fee"** which is calculated according to the rate of license fee and the formula determined by EAC for each financial years pursuant to Article 27 of the Law and Article 3 of Sub-Decree of the Royal Government of Cambodia fixing the maximum of License fee for the electric power services in the Kingdom of Cambodia.

2. Each invoice of monthly license fee shall be due and payable within 14 days after the day on which Licensee receives it.

## 3-SERVICE CONDITIONS

**Condition 7: Conditions on electric power service area**

1. This license grants the right to the licensee to distribute electric power in Samraong Tong and Korng Pisey District, Kampong Speu Province. The authorized distribution area is clearly indicated in schedule 1 of this license (as shown in the attached map).

2. Big consumers and bulk consumers in the distribution area indicated in schedule 1 may have the right to select other supply sources from the transmission line or distribution network of other licensees, if they obtain prior approval from EAC.

**Condition 8: Conditions on electric power service utilities**

1. The licensee shall have the obligation to develop its distribution system in order to supply the electricity to its consumers with efficiency and security. The licensee shall plan and develop its distribution system in confirming with the General Requirement of

បច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំនិងប្រកាសឱ្យប្រើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

Electric Power Technical Standards of the Kingdom of Cambodia issued by Ministry of Industry, Mines and Energy.

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពង្រីក និងកែលំអប្រព័ន្ធចែកចាយរបស់ខ្លួនតាមកម្មវិធីដែលបានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីដល់គ្រប់អ្នកប្រើប្រាស់ក្នុងតំបន់ ។

2. The Licensee shall extent and improve its distribution network in accordance with its plan approved by EAC to ensure the electricity supply to all consumers in the area of distribution.

## លក្ខខណ្ឌទី៩ : លក្ខខណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ

## Condition9: Conditions on distribution system operation

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវដំណើរការការផ្គត់ផ្គង់ និងការចែកចាយរបស់ខ្លួនតាមស្តង់ដាប្រតិបត្តិមួយ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមតាមមាត្រា៣ និង៧(ង) របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

1. The Licensee shall conduct its Supply and Distribution Operation to meet the standards of performance determined by EAC pursuant to Article 3 and 7(e) of the Electricity Law of the Kingdom of Cambodia.

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវរៀបចំឱ្យមានប្រភពអគ្គិសនីគ្រប់គ្រាន់មួយសម្រាប់ផ្គត់ផ្គង់ឱ្យអតិថិជនរបស់ខ្លួន ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធានានូវល័ក្ខខ័ណ្ឌដូចខាងក្រោម :

(ក)- មិនត្រូវមានការកាត់ផ្តាច់លើសពីរយៈពេលស្តង់ដា ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និង

(ខ)- តង់ស្យុង និងប្រេកង់អគ្គិសនី មិនត្រូវហួសកំរិតព្រំដែនដំណើរការជាធម្មតាដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

2. The Licensee shall make available sufficient electricity for supply to its consumers. Licensee shall ensure the following conditions:

(a) Supply will not be discontinued for more than the permissible time approved by EAC; and

(b) The voltage or frequency of electricity will not go beyond the operational limits approved by EAC.

៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមកូដប្រព័ន្ធចែកចាយមួយ ដែលអាជ្ញាធរអគ្គិសនីកម្ពុជានឹងកំណត់នៅពេលក្រោយ ។

3. The Licensee shall comply with the Distribution Code, when approved by EAC.

## លក្ខខណ្ឌទី១០ : លក្ខខណ្ឌចំពោះការធ្វើអាជីវកម្មអគ្គិសនី

## Condition 10: Condition on electric power business

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវដំណើរការ និងគ្រប់គ្រងសេវាកម្មអគ្គិសនីដែលបានផ្តល់ដោយអាជ្ញាប័ណ្ណនេះឱ្យមានប្រសិទ្ធភាព គុណភាព និងតម្លាភាព ដោយអនុលោមតាមល័ក្ខខ័ណ្ឌកំណត់ក្នុងអាជ្ញាប័ណ្ណនេះ និងបទប្បញ្ញត្តិនានា ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

1. The Licensee shall operate and manage the Services provided under this License in an efficient, qualitative and transparent manner in accordance with the requirement of this License and the regulations issued by EAC.

២- វិវាទឬជម្លោះណារវាងអ្នកកាន់អាជ្ញាប័ណ្ណ និងភាគីទី៣ដែលទាក់ទងនឹងកិច្ចព្រមព្រៀងណាមួយក្នុងការទិញអគ្គិសនីជាមួយភាគីទី៣ត្រូវដោះស្រាយអនុលោមតាមបញ្ញត្តិក្នុងកិច្ចព្រមព្រៀងជាមួយភាគីនោះ ។

2. Any dispute or difference between Licensee and third party relating to any agreement for purchase of electricity from third party shall be settled according to the provision in that agreement.

៣- អ្នកកាន់អាជ្ញាប័ណ្ណពុំត្រូវចុះកិច្ចព្រមព្រៀងជាមួយភាគីទី៣ ដើម្បីទិញអគ្គិសនីដោយគ្មានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

3. The Licensee shall not enter into arrangements with third party for purchase of electricity without prior approval of EAC.

៤- អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវប្រើប្រាស់អចលនទ្រព្យនៃអាជីវកម្មរបស់អាជ្ញាប័ណ្ណនេះសម្រាប់គោលបំណងអ្វីក្រៅពីអាជីវកម្មដែលបានអនុញ្ញាត ដូចកំណត់ក្នុងឯកសារនេះ ដោយពុំមានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

4. The Licensee shall not use the assets of this License's business for the purpose other than the business permitted in this document without prior approval of EAC.

| | |
|---|---|
| ៥- អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវទទួលយកឬចូលរួមជាមួយអាជីវកម្មបន្ថែមណាមួយទៀតទេ រួមទាំងអាជីវកម្មផលិត បញ្ជូន ចែកចាយ ឬលក់ថាមពល ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 5. The Licensee shall not acquire any additional business, including the business of generating, transmitting, distribution or supply of energy, without the prior approval in writing of EAC. |
| ៦- នៅគ្រប់ពេល អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវប្រគល់អាជ្ញាប័ណ្ណ ឬផ្ទេរការកាន់កាប់របស់ខ្លួន ឬផ្នែកណាមួយរបស់វា ដោយលក់ បញ្ចាំ ជួល ប្តូរ ឬផ្សេងពីនេះ បើពុំមានកំណត់ក្នុងកិច្ចព្រមព្រៀងទិញអគ្គិសនី និងពុំមានការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 6. The Licensee shall not, at any time, assign his License or transfer his undertaking, or any part thereof, by sale, mortgage, lease, exchange or otherwise, unless specified in PPA and approved by EAC. |
| ៧- កិច្ចព្រមព្រៀងណាមួយពាក់ព័ន្ធជាមួយកិច្ចការ ដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី៣-៤-៥ និងទី៦ខាងលើ បើពុំមានការឯកភាពជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាទេ ត្រូវចាត់ទុកថាជាមោឃៈ និងត្រូវទុកជាការរំលោភលើល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ។ | 7. Any agreement relating to any transaction of the nature described above at paragraph 3, 4, 5 and 6, unless made with the prior written consent of EAC, shall be void and would constitute violation of Conditions of License. |
| ៨- អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តថ្លៃលក់អគ្គិសនី និងបន្ទុកផ្សេងៗ ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 8. The Licensee shall implement the tariff and charge approved by EAC for the Licensee. |
| **ល័ក្ខខ័ណ្ឌទី១១ : ល័ក្ខខ័ណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន** | **Condition 11: Condition on electric power supply to customer** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីល័ក្ខខ័ណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ | 1. The Licensee shall comply with the EAC's Regulation on general conditions of supply of electricity in the Kingdom of Cambodia. |
| ២- ក្នុងការចែកចាយអគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវរើសអើងរវាងបុគ្គល ឬក្រុមបុគ្គលណាមួយជាមួយបុគ្គល ឬក្រុមបុគ្គលណាមួយទៀតឡើយ ។ | 2. In the provision of electricity, the Licensee shall not discriminate between persons or classes of person. |
| ៣- អ្នកកាន់អាជ្ញាប័ណ្ណ (និងធានាថាភ្នាក់ងាររបស់ខ្លួន) ត្រូវធ្វើសកម្មភាពយ៉ាងណាសមស្របដើម្បីការពារ និងទប់ទល់នឹង : | 3. The Licensee shall (and shall ensure that its agents) take all reasonable steps to detect and prevent: |
| (ក)-ការលួចអគ្គិសនីនៅចំណុចផ្គត់ផ្គង់ | (a) the theft of electricity at the point of supply |
| (ខ)-ការធ្វើឱ្យខូចខាតបរិក្ខាអគ្គិសនី, ខ្សែបណ្តាញឬនាឡិកាស្ទង់ណាមួយដែលតាមរយៈវា អតិថិជនបានទទួលការផ្គត់ផ្គង់ | (b) damage to any electrical plant, electric line or electricity meter through which the consumer is supplied; and |
| (គ)-ការប៉ះពាល់ដល់នាឡិកាស្ទង់ណាមួយ ដែលតាមរយៈវាអតិថិជនបានទទួលការផ្គត់ផ្គង់ | (c) interference with any electricity meter through which such premises are supplied. |
| ៤- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបញ្ចូលក្នុងបញ្ញត្តិនៃកិច្ចសន្យាផ្គត់ផ្គង់ជាមួយអតិថិជនថា អតិថិជនត្រូវផ្តល់ពត៌មានឱ្យបានឆាប់រហ័សតាមដែលអាចអនុវត្តទៅបានឱ្យអ្នកកាន់អាជ្ញាប័ណ្ណនូវឧប្បត្តិហេតុណាមួយ ដែលគេជឿជាក់ថា : | 4. The Licensee shall include in the provisions of supply contract with the customer that the customer shall, as soon as is reasonably practicable and possible, inform the Licensee of any incident where it has reason to believe: |
| (ក)-មានការខូចខាតបរិក្ខាអគ្គិសនី ខ្សែបណ្តាញ ឬនាឡិកាស្ទង់អគ្គិសនី ឬ | (a) there has been damage to electrical plant, electric line or meter; or |
| (ខ)-មានការប៉ះពាល់នាឡិកាស្ទង់ ដោយធ្វើឱ្យលំអៀងដល់ការកត់ត្រា ឬទប់ស្កាត់មិនឱ្យកត់ត្រាបរិមាណអគ្គិសនីដែលបានផ្គត់ផ្គង់ | (b) there has been interference with the meter to alter its register or prevent it from duly registering the quantity of electricity supplied. |

៥- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីស្នើសុំការយល់ព្រមលើនីតិវិធីរបស់ខ្លួន សម្រាប់ដោះស្រាយពាក្យបណ្តឹងរបស់អតិថិជនចំពោះខ្លួន ។

៦- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង្កើតនិងដំណើរការនូវសេវាផ្តល់ព័ត៌មានមួយ សម្រាប់ផ្តល់ព័ត៌មានឱ្យអតិថិជនណាមួយដែលចង់ដឹងពីព័ត៌មាន ការណែនាំ ឬការផ្តល់យោបល់ពីបញ្ហាណាមួយឬឧបត្តិហេតុណាមួយ ក្នុងសេវាកម្មចែកចាយអគ្គិសនីរបស់ខ្លួន ។

**លក្ខខណ្ឌទី១២ : លក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ**

១- អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវបោះបង់ចោល ឬបដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ មុនពេលមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ អចលនទ្រព្យអាជីវកម្ម មានន័យថា គឺជាអចលនទ្រព្យណាមួយដែលនៅពេលនោះជាផ្នែកមួយនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ មជ្ឈមណ្ឌល បញ្ជាណាមួយ ដែលប្រើប្រាស់ជាមួយប្រព័ន្ធចែកចាយនោះ និងសិទ្ធិ កម្មសិទ្ធិ ឬអត្ថប្រយោជន៍ណាមួយលើដី ដែលអចលនទ្រព្យនោះស្ថិតនៅ ។

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរនូវសំណើជាលាយលក្ខណ៍អក្សរស្តីពីគោលបំណងរបស់គេក្នុងការបោះបង់ចោល ឬបដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ ដោយភ្ជាប់ជាមួយព័ត៌មានបន្ថែមផ្សេងទៀតតាមដែលអាជ្ញាធរស្នើសុំ ពាក់ព័ន្ធជាមួយនឹងអចលនទ្រព្យនោះ ឬកាលៈទេសៈនៃការលះបង់ ឬបដិសេធចោលការគ្រប់គ្រងនេះ ឬគោលបំណងនៃបុគ្គលណាមួយ ដែលចង់ទទួលយកឬទទួលគ្រប់គ្រងដំណើរការលើអចលនទ្រព្យនោះ ។

៣- អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ) អាចយល់ព្រម ឬមិនយល់ព្រមនូវសំណើនេះ ។

៤- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវពិគ្រោះយោបល់ជាមួយតំណាងបុគ្គលិកកម្មកររបស់ខ្លួន ដើម្បីបង្កើតឱ្យមានយន្តការ ឬវេទិកាជាប្រចាំមួយ ដើម្បីរួមគ្នាគិតគូរពីបញ្ហារួមពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពរបស់ពួកគេ ។

**លក្ខខណ្ឌទី១៣ : ការទំនាក់ទំនង**

១- រាល់ទំនាក់ទំនងទាំងអស់ពាក់ព័ន្ធជាមួយអាជ្ញាប័ណ្ណនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយយកភាសាខ្មែរជាគោល ។

**លក្ខខណ្ឌទី១៤: លក្ខខណ្ឌលក់មធ្យោបាយចែកចាយក្នុងករណីមានការតំរូវពីអាជ្ញាធរអគ្គិសនីកម្ពុជា**

១- ក្នុងរយៈពេល ៦ខែ បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណនេះ អ្នកកាន់

5. The Licensee shall prepare and submit to EAC its procedure for handling complaint from customers for approval.

6. The Licensee shall establish and operate an information service for use by any customer for the purposes of receiving information, guidance or advice about any matter or incident in its distribution service.

**Condition 12: Conditions on public interest**

1. The Licensee shall not dispose of or relinquish operational control over any relevant asset prior to the written consent from EAC. "Relevant asset" means any asset for the time being forming part of the Licensee's Distribution System, any control center for use in conjunction therewith and any right, title or interest in land upon which any of the foregoing is situated.

2. The Licensee shall give to EAC written proposal of its intention to dispose of or relinquish operational control over any relevant asset, together with such further information as EAC may request relating to such asset or the circumstances of such intended disposal or relinquishment of control or to the intentions in regard thereto of the person proposing to acquire such asset or operational control over such asset.

3. EAC may (following consultation with the Licensee) give consent or refuse consent to this proposal.

4. The Licensee shall consult with appropriate representatives of persons employed by it in order to establish and maintain an appropriate machinery or forum for the joint consideration of matters of mutual concern in respect of the health and safety of such persons.

**Condition 13: Communication**

1. All communications relating to this License shall be written in Khmer as official.

**Condition 14: Sale Condition of distribution facility in the case it is the required from EAC**

1. Within six months after receiving this license, the licensee shall

| | |
|---|---|
| អាជ្ញាប័ណ្ណ ត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាអនុម័ត និងចុះបញ្ជីអចលនទ្រព្យសម្រាប់ធ្វើសេវាកម្មរបស់ខ្លួន។ បញ្ជីនេះត្រូវបញ្ជាក់លម្អិត នៅឆ្នាំចាប់ផ្តើមដំណើរការអាជីវកម្ម និងតំលៃដើមនៃមធ្យោបាយធ្វើសេវាកម្មនីមួយៗ។ បន្ទាប់ពីនោះ នៅរៀងរាល់ឆ្នាំមុនថ្ងៃទី១៥ ខែកុម្ភៈ អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជា កែសម្រួលបញ្ជីមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួនដែលមានជាក់ស្តែង ដល់ថ្ងៃទី៣១ ខែធ្នូ កន្លងមក។ បញ្ជីនេះ ត្រូវបង្ហាញនូវមធ្យោបាយធ្វើសេវាកម្មដែលមានពីដើមឆ្នាំ ដែលបានបន្ថែម ឬលុបចេញក្នុងឆ្នាំ ដោយមានបញ្ជាក់តំលៃមធ្យោបាយធ្វើសេវាកម្មនោះ និងមធ្យោបាយធ្វើសេវាកម្មដែលមាននៅចុងឆ្នាំ។ | submit the list of its facilities for approval and registering at EAC as relevant asset. The list should also give details on year of commissioning and the original cost of each facility. Thereafter, for revision of the list of relevant asset, the licensee shall submit to EAC by $15^{th}$ February each year, the list of its facilities as on $31^{st}$ December of the previous year. The list should indicate the facilities in the beginning of the year, additions made during the year with its cost, deletion made during the year with its original cost and facilities at the end of the year. |
| ២- ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនានា ក្នុងករណីដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណលក់ ឬផ្ទេរមធ្យោបាយធ្វើសេវាកម្មដែលបានចុះបញ្ជីនៅអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យអ្នកបន្តវេនមួយផ្សេងទៀត តាមគោលការណ៍ហិរញ្ញវត្ថុ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។ | 2. Under Electricity Law and Sub-decrees, in the case of revocation of license, EAC can require licensee to sale or transfer its facilities registered with EAC as relevant asset to the successor in accordance with financial principle determined by EAC. |

# ឧបសម្ព័ន្ធទី១

# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

## SCHEDULE 1

## AUTHORIZED DISTRIBUTING AREA

| | |
|---|---|
| ១- តំបន់អនុញ្ញាតដែលក្រុមហ៊ុន **សុខា អេឡិកទ្រីស៊ីធី** មានសិទ្ធិផ្តល់សេវាចែកចាយអគ្គិសនីគឺតំបន់ស្រុកសំរោងទង និងតំបន់ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ | 1. The authorized distribution area, where **Sokha Electricity Co., Ltd** has the right to provide the electricity is at Samraong Tong and Korng Pisey District, Kampong Speu Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ "ផែនទីកំណត់ព្រំប្រទល់ " ដែលភ្ជាប់ជាមួយ ។ | 2. The authorized distribution area is determined by "the boundary map" attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if the licensee intends to request the extension or the additional distribution areas then the licensee shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |

# ឧបសម្ព័ន្ធទី២

# ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ

## SCHEDULE 2

## TERM OF LICENSE REVOCATION

| | |
|---|---|
| ១- អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការដកហូតអាជ្ញាប័ណ្ណណាមួយដែលបានផ្តល់ដោយឯកសារនេះបាន គ្រប់ពេលតាមកាលៈទេសៈដូចខាងក្រោម: | 1. EAC may at any time consider revocation of any of the licenses granted by this License Document under following circumstance: |
| (ក)- ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណសំណូមពរជាលាយលក្ខណ៍អក្សរ ទៅអាជ្ញាធរអគ្គិសនីកម្ពុជា សុំឱ្យដកហូតអាជ្ញាប័ណ្ណនេះ ឬ | (a) if the Licensee requests in writing to EAC that that such license may be revoked; or |
| (ខ)- ប្រសិនបើ ចំនួនទឹកប្រាក់ដែលត្រូវបង់ណាមួយតាមល័ក្ខខ័ណ្ឌទី៦នៃកាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ ទាក់ទងជាមួយអាជ្ញាប័ណ្ណនេះមិនបានទូទាត់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយថ្ងៃដែលកំណត់ឱ្យបង់ ឬមិនបានទូទាត់ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអាជ្ញាធរបានប្រគល់លិខិតជូនដំណឹងឱ្យទៅអ្នកកាន់អាជ្ញាប័ណ្ណថាថ្ងៃទូទាត់បានផុតកំណត់ហើយ ប៉ុន្តែលិខិតជូនដំណឹងនេះមិនត្រូវចេញមុន១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលចំនួនទឹកប្រាក់នេះត្រូវកំណត់ឱ្យបង់ឡើយ ។ | (b) if any amount payable under Condition 6 of General Obligation of Licensee in relation to such license is unpaid 30 days after it has become due or remains unpaid for a period of 14 days after EAC has given the Licensee notice that the payment is overdue provided that no such notice shall be given earlier than the fourteenth day after the day on which the amount payable became due; |
| (គ)- ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិខុសពីល័ក្ខខ័ណ្ឌណាមួយនៃអាជ្ញាប័ណ្ណ និងមិនគោរពតាមបទបញ្ជាចុងក្រោយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការកែតម្រូវកំហុសនេះ ឬ | (c) if the Licensee in the opinion of the EAC has committed a material breach of any of the terms and Conditions of such License and does not comply with a final order of EAC to rectify such breach; or |
| (ឃ)- ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញភារកិច្ច និងកាតព្វកិច្ចដែលបានកំណត់ដោយអាជ្ញាប័ណ្ណនេះឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព,ឬ | (d) if the Licensee in the opinion of the EAC, is not in a position to fully and efficiently discharge the duties and obligations imposed on Licensee by such License; or |
| (ង)- ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិខុសដោយចេតនា និងគ្មានហេតុផលចំពោះល័ក្ខខ័ណ្ឌដែលកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជារួមទាំងច្បាប់ការពារបរិស្ថាន សុវត្ថិភាព សុខភាព ពន្ធដារ ព្រមទាំងការអនុវត្តន៍ ការការពារ និងស្តង់ដានៃប្រព័ន្ធអគ្គិសនី ។ | (e) if in the opinion of EAC the Licensee has committed a willful or unreasonable default to comply with conditions set forth in the rules and regulations adopted by EAC, and the Laws of the Kingdom of Cambodia, including Laws regarding environmental protection, safety, health, taxes, and electric system performance, protection and standards; |
| ២- នៅគ្រប់ពេលអាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលមិនតិចជាង៣ខែទៅអ្នកកាន់អាជ្ញាប័ណ្ណស្តីពីមូលហេតុដែលឈរលើនេះអាជ្ញាប័ណ្ណណាមួយតម្រូវឱ្យដកហូត ។ | 2. EAC may at any time give not less than 3 months notice in writing to the Licensee stating the grounds on which any License is proposed to be revoked. |
| ៣- ជំនួសឱ្យការដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុញ្ញាតឱ្យអាជ្ញាប័ណ្ណនេះបន្តនៅជាធរមានបន្តទៀត បើសិនជាមានល័ក្ខខ័ណ្ឌបន្ថែមទៀត ដែលយល់ថាគួរត្រូវដាក់ជំនួស រួចល័ក្ខខ័ណ្ឌបន្ថែមដែលត្រូវដាក់នេះ ត្រូវចងភ្ជាប់តាមផ្លូវច្បាប់ និងត្រូវប្រតិបត្តិតាមដោយអ្នកកាន់អាជ្ញាប័ណ្ណ, និងត្រូវចូលជាធរមានដូចបានកំណត់ក្នុងអាជ្ញាប័ណ្ណដូច្នេះដែរ ។ | 3. EAC may, instead of revoking any License, permit it to remain in force subject to such further terms and conditions as considered fit to impose and any further terms or conditions imposed shall be binding upon and be observed by the Licensee, and be of like force and effect as if they were contained in the License. |

# ឧបសម្ព័ន្ធទី៣
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ

**SCHEDULE 3**

**OWNERSHIP OF LICENSEE**

| | |
|---|---|
| ១- អ្នកកាន់អាជ្ញាប័ណ្ណរួមមានម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីក្នុង **ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី** ដែលម្ចាស់ភាគហ៊ុនមានសមាសភាពដូចខាងក្រោម: | 1. The licensee has the following registered owners of the **Sokha Electricity Co., Ltd** with ownership of the shares are: |
| (ក) លោកស្រី **ហេង សុខា** មានចំនួន ៣០០ ភាគហ៊ុន ពីលេខ ០០០១ ដល់លេខ ០៣០០ | (a) Mrs. **HENG SOKHA**: 300 shares from 0001 to 0300. |
| (ខ) លោកស្រី **ចាន់ គីម** មានចំនួន ៣០០ ភាគហ៊ុន ពីលេខ ០៣០១ ដល់លេខ ០៦០០ | (b) Mrs. **CHAN KIM**: 300 shares from 0301 to 0600. |
| (គ) លោក **ហេង វន្ថា** មានចំនួន ៤០០ ភាគហ៊ុន ពីលេខ ០៦០១ ដល់លេខ ១០០០ | (c) Mr. **HENG VANTHA**: 400 shares from 0601 to 1000. |
| ២- យោងតាមមាត្រា ៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀតដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ ក្នុងករណីជាក់លាក់ណាមួយដើម្បីជាផលប្រយោជន៍សាធារណៈ: អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីសម្រេចអនុញ្ញាតឱ្យបាន ។ | 2. Refer to Article 45 of the Electricity Law of the Kingdom of Cambodia, the above registered owners shall not own shares in or have any other direct financial interests in any other licensee without written permission from EAC. EAC may permit in specific cases in public interest. |